ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ: ១៤១ ប្រក.បស្ត

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអាជីវកម្មរ៉ែ សំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន** **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៩៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- យោងការចាំបាច់របស់ក្រសួងបរិស្ថាន និងក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ ១.**

ប្រកាសនេះមានគោលបំណងធ្វើចំណាត់ថ្នាក់គម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ មានដូចជាថ្មកំបោរ ថ្មម៉ាប ថ្មភក់ ថ្មបំបែក ថ្មបាយក្រៀម ក្រួស ខ្សាច់ ឡាតេរីត អាចម៍ដី ដីឥដ្ឋ ហ្គូស្វាត កៅឡាំង ។ល។ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច មានដូចជា រ៉ែមាស រ៉ែត្បូង ដែលតម្រូវឱ្យមានកិច្ចសន្យាការពារបរិស្ថាន ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**ប្រការ ២.**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច ត្រូវរៀបចំកិច្ចសន្យាការពារបរិស្ថាន ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដោយមានការឯកភាពជាផ្លូវការពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចេញអាជ្ញាបណ្ណធនធានរ៉ែដោយក្រសួងរ៉ែ និងថាមពល ឬមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត។

**ប្រការ ៣.**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀត ដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច ដែលមានផ្ទៃដីសរុបតិចជាង ឬស្មើ ០១(មួយ) ហិកតា ត្រូវមានត្រឹមកិច្ចសន្យាការពារបរិស្ថាន ដោយមានការឯកភាពជាផ្លូវការពីមន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចេញអាជ្ញាបណ្ណធនធានរ៉ែដោយមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត លើកលែងតែប្រភេទគម្រោងមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ដែលមន្ទីរបរិស្ថានរាជធានី ខេត្ត តម្រូវឱ្យមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង។ ប្រភេទគម្រោងស្ថិតក្នុងតំបន់ហាមឃាត់ដែលកំណត់ដោយមន្ទីរបរិស្ថាន ឬមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត នឹងមិនត្រូវបានអនុញ្ញាតឡើយ។

សុពលភាពនៃលិខិតឯកភាពលើកិច្ចសន្យាការពារបរិស្ថានមានរយៈពេល ០១(មួយ) ឆ្នាំ។

**ប្រការ ៤.**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាអាជីវកម្មខ្នាតតូច ដែលមានផ្ទៃដីសរុបធំជាង ០១(មួយ)ហិកតា ដល់ ១០(ដប់) ហិកតា ត្រូវរៀបចំកិច្ចសន្យាការពារបរិស្ថាន ដោយមានការឯកភាពជាផ្លូវការពីក្រសួងបរិស្ថាន ដើម្បីជាមូលដ្ឋានក្នុងការចេញអាជ្ញាបណ្ណធនធានរ៉ែ ដោយក្រសួងរ៉ែ និងថាមពល លើកលែងតែប្រភេទគម្រោងដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គមនោះ ក្រសួងបរិស្ថានតម្រូវឱ្យមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។ ប្រភេទគម្រោងស្ថិតក្នុងតំបន់ហាមឃាត់ដែលកំណត់ដោយក្រសួងបរិស្ថាន ឬក្រសួងរ៉ែ និងថាមពលនឹងមិនត្រូវបានអនុញ្ញាតឡើយ។

សុពលភាពនៃលិខិតឯកភាពលើកិច្ចសន្យាការពារបរិស្ថាន មានរយៈពេល ០២(ពីរ) ឆ្នាំ។

**ប្រការ ៥.**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ដែលមានផ្ទៃដីសរុបធំជាង ១០(ដប់) ហិកតា ដល់ ៤០(សែសិប) ហិកតា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដោយមានការឯកភាពជាផ្លូវការពីក្រសួងបរិស្ថាន ដើម្បីជាមូលដ្ឋានក្នុងការចេញអាជ្ញាបណ្ណធនធានរ៉ែ ដោយក្រសួងរ៉ែ និងថាមពល លើកលែងតែប្រភេទគម្រោងដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម នោះក្រសួងបរិស្ថានតម្រូវឱ្យមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។ ប្រភេទគម្រោងស្ថិតក្នុងតំបន់ហាមឃាត់ដែលកំណត់ដោយក្រសួងបរិស្ថាន ឬក្រសួងរ៉ែ និងថាមពលនឹងមិនត្រូវបានអនុញ្ញាតឡើយ។

សុពលភាពនៃលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង មានរយៈពេល ១០(ដប់) ឆ្នាំ។

**ប្រការ ៦.**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងធ្វើអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ដែលមានផ្ទៃដីសរុបធំជាង ៤០(សែសិប)ហិកតា ឡើងទៅ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដោយមានការឯកភាពជាផ្លូវការពីក្រសួងបរិស្ថាន ដើម្បីជាមូលដ្ឋានក្នុងការចេញអាជ្ញាបណ្ណធនធានរ៉ែដោយក្រសួងរ៉ែ និងថាមពល។ ប្រភេទគម្រោងស្ថិតក្នុងតំបន់ហាមឃាត់ដែលកំណត់ដោយក្រសួងបរិស្ថាន ឬក្រសួងរ៉ែ និងថាមពលនឹងមិនត្រូវបានអនុញ្ញាតឡើយ។

សុពលភាពនៃលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ មានរយៈពេល ១០(ដប់) ឆ្នាំ។

**ប្រការ ៧.**

នីតិវិធី និងរយៈពេលនៃការឆ្លើយតបទៅនឹងសំណើសុំធ្វើកិច្ចសន្យាការពារបរិស្ថាន ត្រូវអនុវត្តអនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងបរិស្ថាន រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នីតិវិធី និងរយៈពេលនៃការឆ្លើយតបទៅនឹងសំណើសុំពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវអនុវត្តអនុលោមតាមអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**ប្រការ ៨.**

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ត្រូវសហការជាមួយនាយកដ្ឋានរ៉ែសំណង់ និងនាយកដ្ឋានអាជីវកម្មរ៉ែ នៃក្រសួងរ៉ែ និងថាមពល ធ្វើការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកចំពោះគម្រោងអាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ ឬរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច ក្នុងគោលបំណងទប់ស្កាត់រាល់បទល្មើសបរិស្ថានដែលទាក់ទងនឹងការធ្វើអាជីវកម្មធនធានរ៉ែ។

**ប្រការ ៩.**

ប្រកាសអន្តរក្រសួងលេខ ០១៤២ រថ.នក.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងធ្វើអាជីវកម្មខ្សាច់គ្រប់ប្រភេទ រវាងក្រសួងរ៉ែ និងថាមពល និងក្រសួងបរិស្ថាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០.**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងបរិស្ថាន និងក្រោមឱវាទក្រសួងរ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១០ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ